ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...៣៤៣៤...អពដ

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពីការរំលឹកការបិទតែមប្រើអាករសម្រាប់បារី

កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងស្តីពីការបិទតែមប្រើអាករសម្រាប់បញ្ជាក់ការបង់ប្រាក់អាករពិសេស និងសេវាមួយចំនួនសម្រាប់បារីដល់ក្រុមហ៊ុននាំចូលបារី សហគ្រាសផលិតបារីក្នុងស្រុក អ្នកប្រកបអាជីវកម្មបារីលក់ដុំ លក់រាយទាំងអស់ ។ បច្ចុប្បន្ន អគ្គនាយកដ្ឋានពន្ធដារបានពិនិត្យឃើញថាមានក្រុមហ៊ុនបារីមួយចំនួនបានអនុវត្តត្រឹមត្រូវការបិទតែមប្រើអាករ ប៉ុន្តែនៅមានក្រុមហ៊ុននាំចូលបារី សហគ្រាសផលិតបារីក្នុងស្រុក អ្នកប្រកបអាជីវកម្មបារីលក់ដុំ លក់រាយ មួយចំនួនមិនបានអនុវត្តការបិទតែមប្រើអាករ ឬអនុវត្តមិនបានត្រឹមត្រូវការបិទតែមប្រើអាករនេះឡើយ ហើយបានធ្វើចរាចរលក់នៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុវត្តនូវការបិទតែមប្រើអាករនេះ ។

អគ្គនាយកដ្ឋានពន្ធដារ សូមរំលឹកជូនដំណឹងដល់ក្រុមហ៊ុននាំចូលបារី សហគ្រាសផលិតបារីក្នុងស្រុក អ្នកប្រកបអាជីវកម្មបារីលក់ដុំ លក់រាយទាំងអស់ ត្រូវអនុវត្តការបិទតែមប្រើអាករដូចមានចែងក្នុងប្រកាសលេខ ៥៣៩ សហវ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៤ ឱ្យបានត្រឹមត្រូវ ។ ក្នុងនោះ ម៉ាកបារីដែលពុំមានបិទតែមប្រើអាករមាន ចំនួន ៨៧ ប្រភេទ គឺ ÷ Esse, Black Stone, Vites, Mond, Just Black, June Slims, Gold Seal, Black Devil, Marce, Oris, Cigars, Raison, Chungwa, Advance, Vimiger, Leomonmini, Black vanilia, Cohiba, Sewels, Grorge Karelias And Song, Panter, Lips, Butter Fly, Hav-A-Tampa, Black, Gala, Vities, 1881, Capital, Ligun, Yuxi, Honghe, Baisha, Double Happiness(Shuangxi), Panda, Peony, Longfeng, Ashima, Camel, Gentle, 1973, Hongtashan, Huanghelou, Nanjing, Wu Yeshen, Furong Wang, Nise, Zest, June, Golden Deer, Yun Yan, Gui Yan, Step Wolves, Sequoi a, Su Yan, Vibes, King Eward, Agio, Pine, Five, Rave, GD, R.G.D., Win, Marble, Kiss, Richmond, Kent, B&H, Queen, Jewels, Good Time, Milano, Goldenleaf, Villiger, HANDELS GOLD, SWISHER SWEETS, Dutch Masters, Captain Black, BORKUM RIFF, BALMORAL, DON DIEGO, MONTECRISTO, PARTAGAS, ROMEO Y JULIETA, SUN GROWN, Punch Punch ។

ក្នុងករណី ក្រុមហ៊ុនមិនបានបិទតែមប្រើអាករ ឬបិទតែមប្រើអាករក្លែងក្លាយ ឬបិទតែមប្រើអាករដែលបានប្រើប្រាស់រួចហើយ ឬបិទតែមប្រើអាករមិនត្រឹមត្រូវ អគ្គនាយកដ្ឋានពន្ធដារនឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនឹងធ្វើការឃាត់ទុកបារីទាំងនោះ ហើយត្រូវទទួលរងនូវទោសទណ្ឌពីបទគេចវេះពន្ធ ដូចមានចែងក្នុងប្រការ១៦ នៃប្រកាសលេខ ៥៣៩ សហវ និងមាត្រា១២៧ មាត្រា១២៨ មាត្រា១៣៣ មាត្រា១៣៥ និងមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ដោយត្រូវទទួលពិន័យជាប្រាក់ពី ១០លានរៀល ដល់ ២០លានរៀល ឬជាប់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ឬទោសទាំងពីរ ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹម និងជឿជាក់ថា លោក-លោកស្រីជាប្រធានក្រុមហ៊ុននាំចូលបារី ប្រធានសហគ្រាសផលិតបារីក្នុងស្រុក អ្នកប្រកបអាជីវកម្មបារីលក់ដុំ លក់រាយទាំងអស់ ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារ នៃសេចក្តីជូនដំណឹងនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

Collection by VCAT Professional Consultant

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh